# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងដយុត្តិធម៌

លេខ ២៩៩ ព្រទ.តយ-២០០៣

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**<u>សូមជម្រាបមក</u>**

**លោកប្រធានតុលាការគ្រប់ខេត្ត ក្រុង**
**លោកព្រះរាជអាជ្ញាអមតុលាការគ្រប់ខេត្ត ក្រុង**

***<u>កម្មវត្ថុ</u>:*** អំពីការសុំកូនយកទៅចិញ្ចឹមរបស់ជនបរទេស តាមរយៈតុលាការ ។

***<u>យោង</u>:*** លិខិតលេខ ៣៣៦កបទ.សក/ចក្រ ចុះថ្ងៃទី២០/០១/២០០៣ របស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ។

ខ្ញុំសូមជម្រាបអស់លោកថា កន្លងមកមានការជួញដូរកុមារតាមរយៈការសុំកូនយកទៅចិញ្ចឹមដោយជនបរទេស ។ ដើម្បីទប់ស្កាត់ការជួញដូរនេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ២៩អនក្រ.បក ចុះថ្ងៃទី១៤-០៣-២០០១ ស្តីពីការសុំទារកកំព្រា ឬកុមារកំព្រាយកទៅចិញ្ចឹមជាកូននៅបរទេស ។

បច្ចុប្បន្ននេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិបានសង្កេតឃើញថាមានជនបរទេសជាច្រើនបានគេចវេសនីតិវិធីនៃការសុំកូនតាមអនុក្រឹត្យខាងលើ ហើយទៅឃុបឃិតសុំកូន ឬទិញកុមាពីឪពុកម្តាយក្រីក្ររួចទៅសុំតុលាការកាត់សេចក្តីសម្រេច ។ រូបភាពនេះជាការបង្កលក្ខណៈងាយស្រួលមួយដល់ការជួញដូរកុមារកម្ពុជាយើង ដែលយើងត្រូវតែរួមគ្នាទប់ស្កាត់ ។

តាមមាត្រា១១៣ វាក្យខណ្ឌ័ទី១ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារការសុំកូនតាមរយៈតុលាការការអនុវត្តបានតែក្នុងប្រទេសប៉ុណ្ណោះ ។ ចំពោះការសុំកូនដោយជនបរទេសយកទៅចិញ្ចឹមនៅបរទេស ដែលមិនមានច្បាប់ចែងច្បាស់លាស់ត្រូវតែអនុវត្តតាមនីតិវិធីដែលមានចែងក្នុងអនុក្រឹត្យខាងលើ ប្រយោជន៍ងាយស្រួលឱ្យរាជរដ្ឋាភិបាលក្តាប់បានអំពីចំនួនទារក និងកុមារដែលត្រូវសុំយកទៅចិញ្ចឹមជាកូននៅបរទេស ហើយអាចមានលទ្ធភាពតាមដានអំពីសកម្មភាពចិញ្ចឹមរបស់ពួកគេរហូតដល់ទារក និងកុមារទាំងនោះក្លាយជានិតិជន ។

ដូច្នេះចាប់ពីពេលនេះតទៅគ្រប់តុលាការខេត្ត-ក្រុង ត្រូវជៀសវាងការចេញសាលក្រមសម្រេចសេចក្តីប្រគល់ទារក ឬកុមារឱ្យទៅជនបរទេសដែលជាអំពើខុសឆ្គងមួយ ពីព្រោះច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារមិនមានកំណត់ចែងអំពីប្រការនេះឡើយ ហើយបើមានភាគីណាប្តឹងសុំពីរឿងនេះ សូមអស់លោកជួយពន្យល់អោយគេអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យខាងលើ ។

ទទួលបានសេចក្តីណែនាំនេះ សូមអស់លោកយកស្មារតីទទួលខុសត្រូវខ្ពស់អនុវត្តឱ្យមានប្រសិទ្ធភាព ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣

**រដ្ឋមន្ត្រី**

** អាង វង្សវឌ្ឍានា**

ចម្លងជូន
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- តុលាការកំពូល
- មហាអយ្យការតុលាការកំពូល
- សាលាឧទ្ធរណ៍
- មហាអយ្យការអមសាលាឧទ្ធរណ៍
- ដើម្បីជ្រាប ។